**សេចក្តីប្រកាសព័ត៌មាន**

**ទំនាក់ទំនង:** *នៅភ្នំពេញ:* ប៊ូ សារឿន (៨៥៥) ០២៣-២១៧-៣០១
sbou@worldbank.org

# របាយការណ៍ថ្មីរបស់ធនាគារពិភពលោកនិយាយថា ប្រទេសកម្ពុជាចាំបាច់ត្រូវដោះស្រាយឧបសគ្គចំពោះកំណើនអនាគត

**ភ្នំពេញ ថ្ងៃទី ៥ ខែកុម្ភៈ ឆ្នាំ ២០០៩** - របាយការណ៍ថ្មីរបស់ធនាគារពិភពលោកស្តីពីប្រទេសកម្ពុជាដែលត្រូវបានផ្សព្វផ្សាយនៅថ្ងៃព្រហស្បតិ៍នេះ និយាយថា នៅពេលដែលប្រទេសកម្ពុជាដោះស្រាយផលប៉ះពាល់ចំពោះមុខនៃវិបត្តិពិភពលោកបច្ចុប្បន្ន ប្រទេសក៏ចាំបាច់ត្រូវដោះស្រាយផងដែរនូវកត្តាក្នុងប្រទេសនានាដែលអាចរារាំងដល់កំណើនសេដ្ឋកិច្ចអនាគត។

លោក **ឈីម៉ាវ ហ្វាន** ប្រធានគ្រប់គ្រងធនាគារពិភពលោកប្រចាំប្រទេសកម្ពុជា បានមានប្រសាសន៍ថា: *"របាយការណ៍នេះគឺជាការរួមចំណែកចុងក្រោយបំផុតរបស់យើងចំពោះការពិភាក្សាអំពីកំណើននៅកម្ពុជា"* របាយការណ៍នេះមានចំណងជើងថា ***កំណើនសេដ្ឋកិច្ចយ៉ាងលឿននៅក្នុងបរិយាកាសប្រឈមមួយ*** របាយការណ៍នេះរៀបចំដោយផ្អែកលើការវិភាគ និងលើការសិក្សាមានស្រាប់ជាច្រើន។ របាយការណ៍នេះកំណត់សក្តានុពលប្រភពកំណើន ក៏ដូចជាឧបសគ្គសំខាន់ៗ និងលើកឡើងនូវជម្រើសគោលនយោបាយនានា ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ។

នៅក្នុងទសវត្សរ៍កន្លងទៅនេះ ប្រទេសកម្ពុជាសម្រេចបានវឌ្ឍនភាពដ៏គួរឱ្យកត់សម្គាល់នៅក្នុងវិស័យមួយចំនួន។ សន្តិភាពនិងស្ថេរភាពបានអនុញ្ញាតឱ្យប្រជាពលរដ្ឋកម្ពុជាសាមញ្ញអាចមានជីវិតរស់នៅធម្មតា ហើយរាជរដ្ឋាភិបាលអាចផ្តល់សេវាចាំបាច់ជាមូលដ្ឋានជូនប្រជាជន។ ជាមួយលទ្ធភាពទទួលបានការថែទាំសុខភាពនិងទឹកស្អាតកាន់តែប្រសើរឡើង ប្រជាជនកម្ពុជាទូទៅ ពេលនេះមានអាយុវែងជាងកាលពីមុន។ កុមារកម្ពុជាកាន់តែច្រើនឡើងក៏កំពុងតែទៅសាលារៀនផងដែរនៅពេលបច្ចុប្បន្ននេះ។

ក្នុងទសវត្សរ៍កន្លងទៅនេះ សេដ្ឋកិច្ចកម្ពុជាកើនឡើងយ៉ាងលឿន។ កំណើនផលិតផលក្នុងស្រុកសរុប (GDP) មានអត្រាជាមធ្យម ៩,៨ ភាគរយរៀងរាល់ឆ្នាំ និង មានកម្រិតខ្ពស់ជាង ១០ ភាគរយក្នុងរយៈពេលបួនឆ្នាំជាប់ៗគ្នាដែលបញ្ចប់នៅក្នុងឆ្នាំ ២០០៧។ កំណើនដ៏គួរឱ្យកត់សម្គាល់នេះ បានបង្កើតឱកាសការងារជាច្រើននៅក្រៅវិស័យកសិកម្មដែលជួយស្រោចស្រង់ប្រជាជនកម្ពុជារាប់លាននាក់ឱ្យរួចចាកផុតពីភាពក្រីក្រ។ ទិន្នន័យថ្មីៗបានបង្ហាញថាចំនួន

ប្រជាជនដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រនៅប្រទេសកម្ពុជា បានធ្លាក់ចុះដល់ ៣០ ភាគរយក្នុងឆ្នាំ ២០០៧ ប្រៀបធៀបទៅ នឹង ៤៥-៥០ ភាគរយក្នុងអំឡុងពេលឆ្នាំ ១៩៩៣/១៩៩៤។

ប៉ុន្តែរបាយការណ៍ធនាគារពិភពលោកថ្មីនេះ គូសបង្ហាញថាកំណើនត្រូវបាននាំមុខជាចម្បងដោយវិស័យចំនួនបួនៈ កាត់ដេរ ទេសចរណ៍ សំណង់ និង កសិកម្ម។ ដោយសារការពឹងផ្អែករបស់ខ្លួនលើវិស័យមួយចំនួនតូចនេះ និង លើការហូរចូលវិនិយោគបរទេសផ្ទាល់ ប្រទេសកម្ពុជាមានលក្ខណៈងាយរងគ្រោះចំពោះការថយចុះពិភពលោកដូចប្រទេសអាស៊ីអគ្នេយ៍ជិតខាងរបស់ខ្លួនអញ្ចឹងដែរ។ ប្រការនេះកើតឡើងទោះបីជាធនាគារពាណិជ្ជរបស់ប្រទេសមិនបានរងផលប៉ះពាល់ដោយផ្ទាល់ពីវិបត្តិហិរញ្ញវត្ថុក្តី។

លោក ស្ទេហ្វាន់ ហ្គីមបើត **(Stephane Guimbert)** អ្នកសេដ្ឋកិច្ចជាន់ខ្ពស់នៃធនាគារពិភពលោកនៅភ្នំពេញ ដែលបានដឹកនាំក្រុមរៀបចំរបាយការណ៍នេះ មានប្រសាសន៍ថា *"កត្តាមួយចំនួនដែលបានរួមចំណែកដល់កំណើនក្នុងរយៈពេលកន្លងមកនេះគឺជាឱកាសតែមួយដង ឬ មិនត្រូវបានរំពឹងថានឹងបន្តល្អប្រសើរឡើងនៅក្នុងអនាគតដ៏ខ្លីនេះទេ" ការប្រើធនធានធម្មជាតិដោយគ្មាននិរន្តរភាព ក៏គម្រាមកំហែងធ្វើឱ្យហិនហោចផងដែរនូវភោគទ្រព្យជាតិដែលកំណើនមួយផ្នែកធំពឹងផ្អែកលើ។ ម្យ៉ាងទៀត កង្វះខាតតម្លាភាពនិងគណនេយ្យភាពនៅក្នុងប្រទេស នឹងបន្តរារាំងដល់អាជីវកម្ម ដែលវាគឺជាប្រផ្នូលមិនល្អសម្រាប់កំណើនអនាគត។*

លោក ហ្គីមបើត បានមានប្រសាសន៍ថា *"ភាគបន្ទាប់ទៅទៀតសំរាប់ប្រទេសកម្ពុជា នៅតែមានលក្ខណៈមិនប្រាកដប្រជាខ្លាំង។ សមិទ្ធិផលនៃទសវត្សរ៏កន្លងទៅមានលក្ខណៈផុយស្រួយណាស់ មូលដ្ឋាននៃកំណើនសេដ្ឋកិច្ចកម្ពុជាមានលក្ខណៈហាក់ដូចជាតូចចង្អៀត ហើយកិច្ចអភិវឌ្ឍន៏បានធ្វើឱ្យប្រជាជនកម្ពុជាក្រីក្រមួយចំនួនមានទ្រព្យស្តួចស្តើង។ ហើយច្រកដែលធ្លាប់បម្រើប្រទេសកម្ពុជាបានល្អ ពោលគឺ ពាណិជ្ជកម្មពិភពលោកនិងលំហូរវិនិយោគ ហាក់ដូចជាបាត់បង់ថាមពលរបស់វា ហើយយ៉ាងហោចណាស់ក៏មួយរយៈដែរ។"*

ថ្វីបើមានបញ្ហាប្រឈមទាំងនេះក្តី ក៏ប្រទេសកម្ពុជាមានសក្តានុពលរឹងមាំមួយដើម្បីបន្តកំណើនខ្ពស់នាអនាគត របាយការណ៍នេះបានលើកឡើង។ ប្រទេសសម្បូណ៌ដី និងធនធានធម្មជាតិផ្សេងទៀតច្រើនគួរសម។ ការប្រើប្រាស់ប្រកបដោយចីរភាព និងការបែងចែកធនធានទាំងនេះប្រកបដោយសមធម៌ អាចផ្តល់កាលានុវត្តភាពកំណើនច្រើនថែមទៀតនាអនាគត។ ទន្ទឹមនឹងនេះ ថ្លៃកម្លាំងពលកម្មនៃប្រទេសកម្ពុជានៅមានលក្ខណៈទាបនៅឡើយ ប្រៀបធៀបជាមួយប្រទេសផ្សេងទៀតនៅក្នុងតំបន់។

ថ្វីបើការនាំចេញប្រមូលផ្តុំភាគច្រើនលើផលិតផលមួយចំនួនតូចទៅកាន់ទីផ្សារគោលដៅមួយចំនួនតូចក្តី ក៏ប្រការនេះផ្តល់នូវឱកាសច្រើនសម្រាប់ពិពិធកម្មនិងកំណើនដែរ។ ការកែលម្អអភិបាលកិច្ចក៏នឹងមានលក្ខណៈអំណោយផលផងដែរចំពោះកំណើនរយៈពេលវែង ដោយសារបរិយាកាសអាជីវកម្មល្អប្រសើរច្រើនតែលើកទឹកចិត្តឱ្យមានសហគ្រាសអាជីវកម្ម ច្រើនថែមទៀត ដែលបង្កើតការងារបន្ថែមទៀតជូនប្រជាជន។

របាយការណ៍នេះលើកឡើងថា ដើម្បីសម្រេចបានសក្តានុពលទាំងអស់ខាងលើនេះ គេចាំបាច់ត្រូវមានសកម្មភាពមុះមុត។

- យុទ្ធសាស្ត្រកំណើនមួយដែលកាន់តែមានមុខព្រួញច្បាស់លាស់ និង ការសម្របសម្រួលកាន់តែប្រសើរឡើងនៅក្នុងចំណោមតួអង្គនិងភាគីពាក់ព័ន្ធផ្សេងៗនៅក្នុងកិច្ចអភិវឌ្ឍន៍នៃប្រទេសកម្ពុជា។
- ការពន្លឿនសមាហរណកម្មប្រទេសកម្ពុជាទៅក្នុងសេដ្ឋកិច្ចតំបន់។
- ការគ្រប់គ្រងធនធានធម្មជាតិកាន់តែមានចីរភាពនិងតម្លាភាព។
- ការកែលម្អបរិស្ថានអាជីវកម្មនិង ការធ្វើឱ្យគោលនយោបាយឧស្សាហកម្មមានលក្ខណៈទំនើប។
- វិនិយោគសាធារណៈកាន់តែច្រើនឡើងលើវិស័យកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ និង អប់រំ។

របាយការណ៍នេះសន្និដ្ឋានថា
ការធ្វើអន្តរាគមន៍របស់រាជរដ្ឋាភិបាលប្រកបដោយជោគជ័យអាចរក្សាកំណើនផលិតផលក្នុង ស្រុកសរុប (GDP) របស់កម្ពុជាក្នុងអត្រា ៦ ឬ ៧ ភាគរយរៀងរាល់ឆ្នាំ។

***របាយការណ៍រក្សាកំណើនលឿន*** ត្រូវបានផ្តួចផ្តើមតាមសំណើរបស់ និងត្រូវបានដឹកនាំដោយ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC) ដែលគឺជាស្ថាប័នស្រាវជ្រាវនិងធ្វើផែនការរបស់រាជរដ្ឋាភិបាលកម្ពុជា។ របាយការណ៍នេះ ត្រូវបានចែកចាយនៅក្នុងវេទិកាសេដ្ឋកិច្ចកម្ពុជាលើកទីបី ដែលគឺជាសន្និសីទមួយដែលត្រូវបានរៀបចំធ្វើដោយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និង ដែលត្រូវបានជួយឧបត្ថម្ភដោយធនាគារអភិវឌ្ឍន៍អាស៊ី កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) និង ធនាគារពិភពលោក។ របាយការណ៍នេះមានដាក់ជូននៅក្នុងគេហទំព័រ www.worldbank.org/kh/growth ។